# នេះពោលអំពីពង្ស “នាគព័ន្ធ”

ការផ្សំគូគ្រងរវាងប្រុសនិងស្រីឱ្យបានគ្នាជាប្ដី-ប្រពន្ធត្រឹមត្រូវតាមលក្ខណៈប្រ ពៃណីនោះ គប្បីសង្កេតមើលសម្ពង្សនាគព័ន្ធ ដើម្បីឱ្យដឹងថាត្រូវនាគ១ជាមួយគ្នា ឬផ្សេងគ្នា ការសង្កេតមើលសម្ពង្សនេះ ដៅចំពោះនិស្ស័យ សេចក្ដីស្នេហា និងទឹកចិត្តភក្ដីដល់គ្នានិងគ្នា ហើយនិងក្រឡាទ្រព្យ៤ក្រឡាផង បើត្រូវការចង់ដឹងពី និស្ស័យរួមគ្នារវាងគូគ្រង ចូរសង្កេតដូចតទៅនេះ :

**រូបភាពទំព័រ (១៧៣)**




**ប្រុស រាប់ពី ១-១២  បើស្រី រាប់ទី ១២-១**

ការមើលសម្ពង្ស "នាគព័ន្ធ"ជាទីសង្កេតទាំងខាងប្រុស និងខាងស្រី ការរាប់កំណត់យកលេខ ១ ឆ្នាំជូត ដល់លេខ ១២ ឆ្នាំកុរ ផ្នែកប្រុស ឯខាងផ្នែកខាងស្រីរាប់ឆ្នាំជូតត្រង់លេខ ១២ ទៅរកលេខ ១ ឆ្នាំកុរ ។

របៀបរាប់យ៉ាងនេះ ដើម្បីពិនិត្យឆ្នាំកំណើត និងឆ្នាំកំណើតទាំងសងខាងឱ្យឃើញថា កំណើតនៅលើលេខណាខ្លួន នាគតែ១ ឬផ្សេងគ្នា កៀក ឬប្រយោលពីគ្នា ជាពិសេសនៅលើក្រឡាអ្វី កាលបើបានឃើញសព្វគ្រប់ហើយ សូមពិចារណា តាមស្លោកទំនាយដូចតទៅ :

បើនៅលើក្បាលនាគទាំង២នាក់ តួនាគតែមួយ យ៉ាងនេះបានគ្នាជាស្វាមីភរិយា មាននិស្ស័យស្របដំណើរគ្នា ទឹកចិត្តរហ័សដូចគ្នា ស្នេហាមានស្នេរភាពដល់គ្នានិងគ្នា ក្រឡាទ្រព្យ រួមគ្នាច្រើនប្រកាន់នាទីខ្ពស់រៀងខ្លួន ។

បើនៅលើក្បាលនាគទាំង២នាក់ តែតួនាគផ្សេងគ្នា សូមជ្រាបថា កាលណានៅរួមគ្នាច្រើនឮមាត់ឮកតមាត់គ្នា ច្រើនមាននិស្ស័យស្របគ្នាដែរ តែសំបូរខាងយកសំនួនលើគ្នាបន្តិច ឆាប់ខឹងឆាប់ជាដាក់គ្នា ការស្នេហាជាធម្មតា មិនសូវ ស្ដាប់ឱវាទគ្នា អាងរៀងខ្លួន ។

បើនៅលើកន្ទុយនាគទាំង២នាក់ តួនាគតែ១ យ៉ាងនេះបានគ្នាជាគូស្វាមីភរិយា មាននិស្ស័យស្របស្រួលនិងគ្នា ស្នេហារស់រវើក តែច្រើនក្តិកក្តក់ដាក់គ្នាបន្តិច មានសេចក្តីសុខ សាមគ្គីល្អ គ្រប់គ្រងគ្នាបានសំបូរសប្បាយដរាបដល់ខ្លួនចាស់ ដៃចាស់ជើងមែនទែន ។

បើនៅលើកន្ទុយនាគទាំង២នាក់ តែតួនាគផ្សេងពីគ្នា សូមជ្រាបថា ការនៅរួមរស់និងគ្នា ច្រើនមានអធ្យាស្រ័យ កន្ទ្រើកឆ្វៀកចេញពីគ្នា ច្រើនច្រណែនឫស្យាដាក់គ្នា ទឹកចិត្តមិនសូវយោគយល់ ស្គាល់ទុកធុរៈគ្នាឡើយ លុះដល់មជ្ឈិមវ័យ ទើបបានសុខស្រួលគ្រាន់បើ ។

បើនៅចំកណ្តាលខ្លួននាគទាំង២នាក់ តួនាគតែ១ យ៉ាងនេះបានល្អ នៅគ្រប់គ្រងគ្នាបានសុខ សំបូរទ្រព្យធន មាន មិត្តច្រើនល្អ និស្ស័យល្អដូចគ្នា ទឹកចិត្តចេះគោរពអាណិតអាសូរដល់គ្នានិងគ្នា រក្សាកេរមរតកគង់ តាំងពីមជ្ឈិមកាលទៅ សុខសប្បាយជាដរាប ។

បើនៅលើខ្លួននាគទាំង២នាក់ តែតួនាគផ្សេងគ្នា សូមជ្រាបថា នៅរួមរស់ជាមួយគ្នាមិនសូវបានស្អិតស្មេរ ច្រើនទុកដាក់ទ្រព្យសម្បត្តិដោយឡែកពីគ្នា និស្ស័យផ្ទុយគ្នារឿយៗ ការយកចិត្តទុកដាក់ដល់គ្នានិងគ្នាមានដោយស្តួចស្តើងណាស់ ច្រើនមើលបំណាំគ្នា ។

បើម្នាក់នៅលើក្បាលនាគ ហើយម្នាក់ទៀតនៅកន្ទុយនាគ តួនាតែ១ យ៉ាងនេះជាមធ្យម នៅរួមរស់ផ្សើរវាសនាទៅវិញទៅមកបាន តែច្រើនមាននិស្ស័យប្រយោលគ្នាម្តងៗ ការងារចាប់ធ្វើតែរៀងៗខ្លួន ទៅណាមកណាមិនសូវជិតតាមគ្នា ស្និទ្ធទេ ទ្រព្យសម្បត្តិជាកណ្តាលតាំងពីដើមដល់ចុង ។

បើនៅលើនាគក្តី ក្បាល កណ្តាលខ្លួននាគក្តី ឬកន្ទុយនាគក្តី រួមលេខជាមួយគ្នាតែលេខណា១ សូមជ្រាបថា យ៉ាងនេះមិនសូវល្អឡើយ ដោយមាននិស្ស័យមិនបានទល់ទ្រគ្នាកើត ទប់ទល់គ្នាមិនបាន គ្មានអ្នកណាយិតយោងអ្នកណា យ៉ាងនេះបើលំបាកលំបាកហួស បើសុខស្រួលក៏ស្រួលពេកកូវ ។

<u>អធិប្បាយ</u> : នាទីសង្កេតពង្ស នាគព័ន្ធ នេះគេច្រើននិយមពិនិត្យពីចរិតលក្ខណៈកំណើតប្រុស-ស្រី ក្នុងខណៈចង សម្ព័ន្ធស្តីដណ្តឹង បើពិនិត្យឃើញពង្សនាគព័ន្ធបានសមគួរហើយ ល្មមប្រើការបាន ទើបព្រមព្រៀងមូលមតិគ្នាជាឯកច្ឆ័ន្ទ ផ្សំឱ្យជាគូគ្រងតាមប្រពៃណី នៅបុរស-ស្រ្តីតាមការគួរដល់កាលវេលា ។

អាការគន់គូរិះរករឿងល្អរបស់គូសម្ព័ន្ធ ដែលមានច្រើនបែបច្រើនបទយ៉ាងនេះ មិនងាយឡើយនិងរកឱ្យបានល្អគ្រប់បែបបទបានទេ តាមពិតរកបានល្អ បានត្រង់ណេះ នៅអាក្រក់ខាងណោះ ទោះជាយ៉ាងនេះក៏ដោយ សូមកត់សម្គាល់ថា ធ្វើយ៉ាងណាឱ្យបានល្អច្រើនភាគជាងការអាក្រក់ ក៏ជាការសំខាន់ណាស់ទៅហើយ ជាពិសេសបើរកបានល្អ១០ ទាំង១០នោះ ជាការប្រពៃពេក ។

....................................................

**រូបភាពទំព័រ ១៧៧**

កាលណាសម្រេចបានមូលមតិគ្នាជាឯកច្ឆន្ទ ព្រមប្រគល់វាសនាបុត្រ និងធីតាឱ្យផ្សំផ្គុំគ្នាពេញលក្ខណៈជាគូស្វាមី ភរិយា តាមសណ្តាប់ប្រវេណី មុននឹងរៀបអាពាហ៍ពិពាហ៍ គួរតែពិចារណាពិនិត្យរកជោគមង្គលសម្រាប់គូបុរស-ស្ត្រីនោះឱ្យបានឃើញទំនងយ៉ាងណាៗ ចូរសង្កេកតាមវេលាជាចាំបាច់រៀបមង្គលការ ដូចតទៅនេះ :

បើចង់ដឹងពីពេលវេលាគួរសម ឬមិនគួរសមនិងរៀបចំពិធីមង្គលការបុរស-ស្ត្រីនោះ ស្ថិតក្នុងវ័យណាក៏ដោយ ចូរយកអាយុទាំង២នាក់បូកគ្នាបានចំនួនប៉ុន្មានត្រាទុក ហើយយកទៅចែកនឹង ៧ ចែកហើយស្រេចសល់នៅប៉ុន្មានប៉ុណ្ណោះ ជាសេសនោះជាស្លោកព្យាករណ៍ដូចតទៅ :

បើបានសេស ១, ៣ និង ០ មិនល្អទេ មិនគួររៀបមង្គលការក្នុងអាយុបានសេសយ៉ាងនេះឡើយ គប្បីលើកពេលវេលាទៅមុខទៀត ។

បើបានសេស ២ , ៥ និង ៦ បានល្អ ហើយគប្បីរៀបចំពិធីមង្គលការក្នុងឆ្នាំនេះ និងបានជោគជ័យគ្រប់គ្រងគ្នាប្រកបទៅដោយសេចក្តីសុខចំរើន អាយុយឺនយូរ មានទ្រព្យធន គួរដល់ការងារដែលបានប្រកប ។

បើបានសេស ៤ ជាមហាឧត្តម គប្បីរៀបពិធីមង្គលការដោយរីករាយចុះ ប្រុស-ស្រីដែលបានរៀបមង្គលការក្នុងរយៈជន្មាយុបានសេសនេះ ប្រសើរលើសសេសទាំងពួងដោយមានយសបរិវា ប្រសើរទៅដោយសេចក្តីសុខ ជាមហាសុខ ។

ម្យ៉ាងទៀតកាលមើលពេលា អាយុដូចខាងលើនេះ បានសមគួរហើយ ប្រសិនបើចង់ពិនិត្យបញ្ជាក់តាមបែបចេក មាស សូមរាប់លេខដែលមាននៅជាប់និងរូបភាពចេកដូចនេះ :

ប្រុសរាប់ពីលេខ ៩ ទៅកាន់លេខ ២ ដល់លេខ៨ វិលជុំត្រាតែដល់អាយុ លើសលេខណា កំណត់លេខនោះទុកមួយ អន្លើ ។

ស្រីចាប់រាប់ពីលេខ ១ វិលមកកាន់លេខ ៨ ដល់លេខ ២ វិលជុំ ត្រាតែគ្រប់អាយុ លើសលេខណា លេខនោះកំណត់ទុកមួយអន្លើ ស្រេចហើយយកលេខទាំង២នាក់នោះមកផ្ទួរផ្ទៀបគ្នាមើល បើឃើញអាយុខាងណាស្ថិតនៅលើលេខ ណានោះគប្បីសង្កេតមើលស្លោកព្យាករណ៍ ដូចតទៅនេះ :

**រូបភាពទំព័រទី ១៧៩**




ចេកមាស

១-ប្រុសបើរាប់ទៅអាយុស្ថិតនៅលើលេខ ១២ មិនគួររៀបអាវាហវិវាហមង្គលការឡើយ ព្រោះនៅត្រង់នេះមានគុណភាពត្រជាក់ណាស់ កាលណាបាននៅរួមរស់ជាមួយភរិយាច្រើនមានចិត្តទម្រន់ប្រចាំ ឬខ្ជិលច្រអូសរង់ចាំរស់ដោយសារភរិយា ពេលានេះហៅថា "**មូលរាសី**" ធ្វើការក្រៅពីរៀបមង្គលការបានប្រសើរទាំងអស់ "ស្រីក៏ដូច្នេះដែរ" ។

២-ប្រុស និង ស្រី បើរាប់ទៅហើយអាយុស្ថិតនៅលើលេខ ៧ ស្រីទៅលើលេខ ៣ យ៉ាងនេះមិនគួរយកធ្វើជាពេលារៀបមង្គលការទេ ព្រោះថាច្រើនរកត្រូវការកាត់យកទ្រព្យ ឥវ៉ាន់សព្វសារពើពេក។

ស្លឹកចេកបែបនេះ ចំពោះពេលារៀបមង្គលការ លោកថាលុះបានគ្នាច្រើនធ្លាក់ជោគអាប់រាសី បណ្តែតវាសនាឱ្យចុះនៅក្រោមផលប្រយោជន៍អ្នកដទៃ ។

៣-ប្រុសនិងស្រី បើរាប់ទៅអាយុស្ថិតនៅលើលេខ ៥ទាំងអស់គ្នាយ៉ាងនេះ មិនគួររៀបជាពេលាការឡើយ ព្រោះថាពេលានៅត្រង់ណេះរងខ្យល់រងកំដៅពេក  វេរលាស់ខ្លាំង កាលណារៀបចំរួចទៅនៅរួមរស់ជាមួយគ្នា មានសភាពទោទន់កម្រើកច្រើន និងបណ្តោយវាសនាឱ្យរប៉ើងរសាត់ទៅតាមឥទ្ធិពលដទៃ១ ឈ្មោះថាជោគរាសី "ចលនារាសី" ។

៤-ប្រុស និងស្រី បើរាប់ទៅអាយុស្ថិតនៅលើលេខ ២, ៤, ៦ និង ៨ គប្បីកំណត់យកជាពេលារៀបមង្គលការ បានជាទីគាប់ប្រសើរសព្វយ៉ាងបាន  ថាបុរស-ស្ត្រីបានរៀបអាពាហ៍ពិពាហ៍ ត្រូវពេលាទាំង៤លេខនេះ សឹងបានសេចក្តីសុខចំរើនសំបូររុងរឿង សុខដុមរមនាមូលមិត្រគ្រួសារ កើតកាលវាលគុម្ពជានិច្ចនិរន្តន៍ ។

ម្យ៉ាងទៀតពេលានេះហៅថា "ពេលាអាយុ" គប្បីពិនិត្យឱ្យហ្មត់ចត់ទៀងទាត់ ដើម្បីកសាងអនាគតរួម ឱ្យមាន វឌ្ឍនភាពមូលធនសម្បត្តិ មានបុត្រប្រកបតាមឱវាទ សំបូរសតិបញ្ញា ស្រឡាញ់ការសិក្សា មានព្យាយាមជាគ្រឹះ ថ្កើងរុងរោចន៍ទៅដោយភ័ព្វវាសនា ។

..........................................

**មើលជោគខ្សែប្រចាំថ្ងៃ**

កាលណាមានភារកិច្ចនិងរៀបមង្គលការ ចង់ដឹងជោគសម្រាប់អ្នកសាមីខ្លួនរៀបមង្គលការ គប្បីរកជោគខែប្រចាំថ្ងៃឱ្យបានដឹងប្រាកដ ។

ការរិះរកជោគប្រចាំថ្ងៃនេះ ជាគុណប្រយោជន៍អាចឱ្យភារៈការមានសុភមង្គលឆ្ពោះទៅកាន់សេចក្តីរុងរឿងសម្រាប់ការរួមរស់ក្នុងវង្សមង្គលគ្រួសារគ្រប់ទេសកាល ព្រមទាំងមានសេចក្តីចំរើន និងអាយុយឺនយូរគ្រប់គ្រងរក្សាគ្នាក្នុងសភាពលូតលាស់សព្វកិច្ចការ ជាពិសេសសុខក្នុងសម្បត្តិយសបរិវា ។

ហេតុនេះ ការរៀបមង្គលការ ជាចាំបាច់បំផុតក្នុងការរកបាននូវជោគខែប្រចាំថ្ងៃ បើបានមូលមតិគ្នាជាឯកច្ឆន្ទថានឹងរៀបចំការក្នុងខែណា គប្បីពិនិត្យបញ្ជាក់មើលក្នុងខែនោះ មានជោគនៅថ្ងៃណា ប៉ុន្មានកើត ឬប៉ុន្មានរោច ជាពិសេសបើរកបានខែណាមានជោគអម ដូចជាខែ១កើត កាន់តែអាទិត្យ ខែនោះមានថ្ងៃអង្គារ៣កើត ជា"សិរិទ្ធិជោគ" និងមានថ្ងៃ ពុធ៤កើត ជាមហាសិទ្ធិជោគ យ៉ាងនេះហៅថាខែមានជោគអម ។

គប្បីកំណត់យកយ៉ាងនេះជាពេលារៀបអាពាហ៍ពិពាហ៍ តែបើរកដូចពោលនេះមិនបានទេ ក៏គប្បីរកតែជោគមួយជាន់ក៏បានមុខនិងសម្រេចយកជោគណាមួយជាពេលា គួរសង្កេតយោលទៅដល់ពេលារួមខ្នើមផង បើរួមខ្នើយបានហើយនោះជាការស្រេច យ៉ាងត្រឹមត្រូវតាមបែបបទប្រពៃណីជាតិប្រាកដ ។

**ប្រាប់របៀបប្រើអក្សរកាត់ក្នុងតារាងនេះ**

**រូបភាពទំព័រ ១៨២**

ខ-សង្កេតន័យក្នុងតារាងនេះ សូមចាំបានថា :

១ ក — គឺ ១កើតកាន់, ៤ ក.ម គឺ ៤កើតមហាសិទ្ធិជោគ, ៩ ក. សំ គឺ ៩កើតសិរិទ្ធិជោគ, ១០ ក. សិ គឺ ១០កើតសិរិទ្ធិជោគ, ៤ រ. សំ គឺ ៤រោចសិរិទ្ធិជោគ, ២ ក.សំ.ម គឺ ២កើតសិរិទ្ធិជោគ និងមហាសិទ្ធិជោគ, ៦ ក. រ. សំ. ម. គឺ ៦កើត រាជាជោគ ។

កាលរើសរកជោគខែបានហើយ គប្បីវៀរថ្ងៃដែលសំពះទទួលស្លាពរជ័យ ត្រូវនឹងថ្ងៃសេសគឺមិនគត់គួរ ដូចជា ៣ កើត ៥រោចជាដើម ហើយជាពិសេសត្រូវលើថ្ងៃ៨កើត ៨រោច ពេញបូណ៌ និងខែដាច់ ក៏គួរតែវៀរជាដាច់ណាត់ ។

អ្នកសាមីមង្គលការទាំងឡាយ សូមសន្និដ្ឋានថា ការរៀបចំខ្លួនដើម្បីឱ្យមានសុភមង្គលក្នុងការរៀបអាពាហ៍ពិពាហ៍ នេះ សូមពិនិត្យជាចុងបំផុត គឺការរួមខ្នើយកិច្ចការទាំងអស់ដែលបានពោលពីខាងដើមទាំងប៉ុន្មាន ក៏ដើម្បីជោគសួស្តីប្រចាំអស់លោកអ្នកមានខ្លួនរៀបអាពាហ៍ពិពាហ៍ ហេតុនេះគួរអស់លោកអ្នកនឹកដល់សុភាសិតបុរាណពោលថា "ល្អ១តៅរើស អស់ចុះទាស់អ្វីនឹងល្អ ១ ចឹប" ។

ជោគរួមខ្នើយមជាការសំខាន់ ហើយចាំបាច់ផង សូមសង្កេតដូចតទៅនេះ :

**ខាងខ្នើត**

(១) ១ កើត ដាំដូងក្បាលចុះក្រោម ជើងឡើងលើ មិនល្អ

(២) ២ កើត ក្បាលឡើងលើស្របគ្នា ជើងចុះក្រោម ល្អ

(៣) ៣ កើត ដេកក្បាលទឹមគ្នា ចុះក្រោម មិនល្អឡើយ

(៤) ៤កើត ក្បាលស្របគ្នាចុះក្រោម ជើងឡើងលើមិនល្អ

(៥) ៥កើត ជើងកន្ទែកចេញពីគ្នា មិនយកជាការឡើយ

(៦) ៦កើត ដេកក្បាលត្រឹមគ្នា កើយខ្នើយជាមួយគ្នា ល្អណាស់

(៧) ៧កើត ក្បាលស្របគ្នាចុះ ជើងឡើងលើ មិនល្អទេ

(៨) ៨កើត ដេកក្បាលចុះក្រោម ជើងឡើងលើ មិនល្អសោះ

(៩) ៩កើត ក្បាលទល់គ្នា មិនបានជាការទេ

(១០) ១០កើត ដេកទឹមក្បាលគ្នាទៅលើ បានល្អ

(១១) ១១កើត ដេកក្បាលចុះក្រោមទាំង២នាក់ មិនល្អទេ

(១២) ១២កើត ក្បាលចុះក្រោម ជើងឡើងលើស្របគ្នា មិនល្អទេ

(១៣) ១៣កើត ក្បាលទឹមគ្នាទៅលើ ល្អណាស់

(១៤) ១៤កើត ក្បាលទល់គ្នា ជើងយះចេញ មិនល្អ

(១៥) ១៥កើត កើតក្បាលចុះក្រោម ជើងឡើងលើ មិនបានជាដាច់ណាត់

ក្បាលទល់ ក្បាលទូល ទឹមគ្នា ក្បាលចុះ ជើងទល់ ជើងយះចេញ

## ខាងរនោច

(១) ១រោច ដេកក្បាលទល់គ្នា យកជាការមិនបានឡើយ

(២) ២រោច ដេកក្បាលរួមខ្នើយជាមួយ ក្បាលចុះក្រោម ជាមធ្យម

(៣) ៣រោច ជើងយះចេញច្រងាងពីគ្នា មិនល្អឡើយ

(៤) ៤រោច រួមខ្នើយតែមួយ ក្បាលទៅលើ ល្អណាស់

(៥) ៥រោច ក្បាលទល់គ្នា ជើងយះចេញ មិនល្អសោះឡើយ

(៦) ៦រោច ដេកក្បាលទល់គ្នា ជើងយះចេញ មិនល្អឡើយ

(៧) ៧រោច ដេកខ្នើយរួមគ្នាឡើងត្រឹមគ្នា ល្អយកជាការបាន

(៨) ៨រោច ដេកក្បាលទល់គ្នា មិនល្អឡើយ

(៩) ៩រោច ដេកក្បាលប្រទល់គ្នា មិនល្អសោះឡើយ

(១០) ១០រោច ដេករួមខ្នើយគ្នាឡើងលើ ល្អគួរយកជាការ

(១១) ១១រោច ដេកទល់ក្បាលគ្នា មិនល្អសោះឡើយ

(១២) ១២រោច ដេកក្បាលប្រទល់គ្នា មិនល្អទេ

(១៣) ១៣រោច ដេកទល់ក្បាលគ្នា មិនយកជាការបានឡើយ

(១៤) ១៤រោច ដេករួមខ្នើយគ្នា ឡើងទៅលើ ល្អយកជាការបាន

(១៥) ១៥រោច ដេកប្រទល់ក្បាលគ្នា មិនល្អទេ

អធិប្បាយ : ជោគរួមខ្នើយ គឺជាជោគជ័យមួយរបស់អ្នកមានភារៈការរៀបចំអាពាហ៍ពិពាហ៍ផ្ទាល់អាត្មា ឬដើម្បី បុត្រធីតា តាមការពិតជោគនេះ បើកាលណាគន់គូរិះរកវេលាបាន ឫក្សល្អថែមទៀត ក្នុងការសំពះទទួលស្លាជ័យ ព្រម ទាំងរកបានជោគខែប្រចាំថ្ងៃល្អរួមជាមួយផងនោះ ជាការប្រពៃក្រៃពេកតាមលទ្ធិហោរនិយម ។

ហេតុនេះហើយបានជាបូរាណខេមរា ចង់បានសេចក្តីសុខ ចំរើនដល់កុលបុត្រ កុលធីតា ដើម្បីមូលត្រកូលគ្នា ចេះ គោរពគ្នានិងគ្នាសន្តោសអត់ឱនឱ្យគ្នាក្នុងវេលាមានការឆ្គង ស្គាល់សុខទុក្ខរវាងគ្នា ស្នេហាមានស្ថេរភាព បានជាខិរិះរកជោគ ឫក្សល្អដើម្បីកំដរនិស្ស័យឬជាមធ្យោបាយដឹកមុខគូជនឈមសំដៅទៅសុភមង្គលឱ្យបានជានិច្ចនិរន្តរ៍ ។

ម្យ៉ាងទៀត សេចក្តីថ្លៃថ្នូររបស់វង្សត្រកូល ក៏បានរក្សាទុកដោយមធ្យមមែន ដោយមិនបណ្តែតបណ្តោយតាមការ ខ្ជីខ្ជាធូរបួសហេតុពេក ជាពិសេសឈ្មោះថាលើកតំកើងប្រពៃណីជាគំរូជាតិត។ទៅទុកជាសណ្តាប់ធ្នាប់សម្រាប់អម្បូរ ។